## នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៩

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 11-Apr-2019, 14:06
CMS/CFO: Sann Rada

### ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ(កោសលុប)

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ត.ក

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ

ហត្ថលេខា:

---

## លិខិតរបស់ នួន ជា ផ្តល់សិទ្ធិឲ្យមេធាវីរបស់គាត់ធ្វើបណ្តឹងសាទុក្ខជំទាស់នឹងសាលក្រម សំណុំរឿង ០០២/០២

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Doreen CHEN

ព្រុំ ផល្លា

Xiaoyang NIE
Marina HAKKOU

ឌី សុជាតា

Gaëlle BUCHET

ផ្ញើជូន៖

**ក្រុមមេធាវីការពារក្តី ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

Stephanie ERIAN
Khady BÂ

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ពេជ អង្គ
Marie GUIRAUD

## ផ្នែកទី ១. សេចក្តីផ្តើម

១. អនុលោមតាមវិធានផ្ទៃក្នុង វិធាន ១០៦, ៧៩ និង ១០៩ និង មាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និង ដើម្បីផលប្រយោជន៍យុត្តិធម៌ សហមេធាវីការពារក្តី នួន ជា (“មេធាវីការពារក្តី”) សូមដាក់ជូននូវលិខិតរបស់ នួន ជា ផ្តល់សិទ្ធិឲ្យមេធាវីការពារក្តីធ្វើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមសំណុំរឿង ០០២/០២ និង ស្នើសុំថា លិខិតនេះត្រូវដាក់ចូលក្នុងសំណុំរឿងដោយដាក់ចំណាត់ថ្នាក់ជាឯកសារសាធារណៈ និង ដាក់បញ្ចូលនៅលើគេហទំព័ររបស់ អវតក នៅមុនពេលដាក់ជូននូវសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ (“សំណើ”)។

## ផ្នែកទី ២. សាវតា

២. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) បានចេញសាលក្រមមិនផ្លូវការនៅក្នុងសំណុំរឿង ០០២/០២ សម្រាប់ នួន ជា និង ខៀវ សំផន (“សាលក្រមសង្ខេប”)[1]។ នៅថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ២០១៩ អង្គជំនុំជម្រះបានចេញសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ (“សាលក្រម”)[2]។

### I. ការឆ្លើយតបរបស់ នួន ជា នៅនឹងសាលក្រមសំណុំរឿង ០០២/០២

៣. នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៩ មេធាវីការពារក្តីបានដាក់សំណើបន្ទាន់ទៅអង្គជំនុំជម្រះតុលាការកំពូល ដើម្បីសុំពេលវេលា និងទំព័របន្ថែមសម្រាប់ដាក់ជូននូវសេចក្តីជូនដំណឹងអំពី

---

[1] “សាលក្រមសង្ខេបរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២” ថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ២០១៨ (“សាលក្រមសង្ខេប”)។

[2] **E465**, “សាលក្រមសំណុំរឿង ០០២/០២” ថ្ងៃទី ១៦ វិច្ឆិកា ២០១៨ [តាមពិត ថ្ងៃទី ២៨ មិនា ២០១៩] (“សាលក្រម”)។

បណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ (“សំណើសុំបន្ថែម”)[3]។ នៅក្នុងចំណោមនោះមេធាវីការពារក្តីបានស្នើពេលវេលាបន្ថែម ដើម្បីដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខចំនួន ១៥០ ថ្ងៃ បន្ថែមលើចំនួនកំណត់ ៣០ ថ្ងៃ (សរុបទាំងអស់ ១៨០ ថ្ងៃ) [4]។ មិនទាន់មានសេចក្តីសម្រេចណាមួយលើសំណើនេះនៅឡើយទេ។

៤. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នៅបន្ទាប់ពីប្រកាសសាលក្រមសង្ខេប នួន ជា បានជម្រាបមេធាវីការពារក្តីរបស់គាត់អំពីបំណងប្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រម។ ហើយគាត់នៅតែបង្ហាញអំពីបំណងដូចគ្នាមកកាន់មេធាវីក្នុងពេលបច្ចុប្បន្ននេះ នៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១៩ ដោយគាត់បានចុះហត្ថលេខាលើលិខិតជាផ្លូវការមួយដើម្បីបញ្ជាក់អំពីបំណងនេះ[5]។ ការបកប្រែលិខិតជាភាសាអង់គ្លេសដោយក្រុមមេធាវីការពារក្តីមានន័យដូចខាងក្រោម៖

> សូមគោរពលោកប្រធាន
>
> ដូចដែលលោកប្រធានបានជ្រាបហើយថា នៅភ្លាមៗបន្ទាប់ពីអង្គជំនុំជម្រះបានប្រកាសសាលក្រមសង្ខេបក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ខ្ញុំបានពិគ្រោះជាមួយសហមេធាវីរបស់ខ្ញុំថា ត្រូវតែធ្វើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រម។
>
> នៅថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ២០១៩ សាលក្រមពេញលេញជាលាយលក្ខណ៍អក្សរត្រូវបានចែកជូន ហើយដូចដែលខ្ញុំបញ្ជាក់ជារើយៗថា គោលបំណងសំខាន់របស់ខ្ញុំគឺដើម្បីជម្រាបការពិតជូនប្រជាជនកម្ពុជា និងសកលលោក។

---

[3] **F40/1.1** “សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែមសម្រាប់ការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២” ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៩ (សំណើលើកទីមួយសុំបន្ថែម)។

[4] **F40/1.1** “សំណើលើកទីមួយសុំបន្ថែម” កថាខណ្ឌ ១ (ក) និង ៦១ (ក)។

[5] លិខិតរបស់ នួន ជា ជូនលោកប្រធាន អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១៩ **(ឯកសារភ្ជាប់ ១)**។

អាស្រ័យហេតុនេះហើយ ខ្ញុំសូមជម្រាបជូនលោកប្រធានថា ខ្ញុំសូមផ្តល់សិទ្ធិ និង អនុញ្ញាតឱ្យសហមេធាវីទាំងពីររបស់ខ្ញុំធ្វើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២។

សូមលោកប្រធានជ្រាប និងទទួលការគោរពអំពីរូបខ្ញុំ
នួន ជា
[redacted]

## II. សុខភាពរបស់ នួន ជា

៥. ដូចដែលអង្គជំនុំជម្រះ និង សាធារណៈជនដឹងហើយថា នួន ជា មានអាយុជិត ៩៣ ឆ្នាំទៅហើយ។ គាត់មានវ័យចាស់ណាស់បើគិតទៅលើបទដ្ឋានអាយុ។ តាមពិតទៅអាយុរបស់គាត់លើស ២៥ ឆ្នាំ ពីអាយុជាមធ្យមរស់នៅរបស់មនុស្សប្រុសសម្រាប់ប្រទេសកម្ពុជា (ដែលមានត្រឹមតែ ៦៧ ឆ្នាំ)[6]។

៦. [redacted]

៧. [redacted]

[6] អង្គការសុខភាពពិភពលោក "ប្រទេសកម្ពុជា" ថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០១៩។

[7] [redacted]

[redacted]

**ផ្នែកទី ៣. ច្បាប់ជាធរមាន**

៨. វិធាន ១០៦ (២) (០៣) និង (៤) ចែងថា៖

២. បណ្តឹងសាទុក្ខ និង បណ្តឹងសាទុក្ខភ្លាមៗ ត្រូវដាក់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង និង ត្រូវចុះក្នុងបញ្ជី បណ្តឹងសាទុក្ខនៃអង្គជំនុំជម្រះសាលាដំបូង។

៣. ជនជាប់ចោទ អាចត្រូវបានតំណាងដោយមេធាវីតំណាង តាមការប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ដើម្បីដាក់ពាក្យបណ្តឹងសាទុក្ខ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែតំណាងដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី។

៤. ការជូនដំណឹងអំពីបណ្តឹងសាទុក្ខ ឬ បណ្តឹងសាទុក្ខភ្លាមៗ ត្រូវចុះហត្ថលេខា ដោយដើមបណ្តឹងសាទុក្ខ ឬ មេធាវីដើមបណ្តឹងសាទុក្ខ និង ចុះហត្ថលេខាសង្ខេបដោយក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង។ **លិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរក៏ត្រូវជូនភ្ជាប់ជាមួយនឹងពាក្យបណ្តឹងនេះ**[9]។

៩. វិធាន ២៣ ស្ទួន (៦) និង មាត្រា ៧ (១) និង ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា បើជនជាប់ចោទទទួលមរណភាព នោះដំណើរការនីតិវិធីព្រហ្មទណ្ឌ និង បណ្តឹងរដ្ឋប្បវេណីនៅមុខ អវតក នឹងត្រូវបញ្ចប់។

១០. វិធាន ៧៩ និង ១០៩ ចែងថា សវនាការនៅចំពោះមុខ អង្គជំនុំជម្រះនេះ និង អង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើងជាសធារណៈ។ ស្រដៀងគ្នានេះដែរ មាត្រា ១៤ (១) នៃ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដោយដាក់បញ្ចូលដោយផ្ទាល់ទៅក្នុង

[8] [redacted]។

[9] វិធានផ្ទៃក្នុង (វិ.លើកទី ៩) ថ្ងៃទី ១៦ មករា ២០១៥ (បញ្ជាក់បន្ថែម)។

ច្បាប់កម្ពុជា ចែងថា "នៅក្នុងការបញ្ចប់ការចោទប្រកាន់ព្រហ្មទណ្ឌទៅលើជនណាមួយ [...] ជននោះមានសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ និង ជាសាធារណៈ"[10]។

## ផ្នែកទី ៤. អំណះអំណាង

### I. នួន ជា មិនត្រូវបានរារាំងមិនឲ្យដាក់ជូននូវការផ្ដល់សិទ្ធិឲ្យធ្វើបណ្ដឹងសាទុក្ខនៅក្នុងដំណាក់កាលនេះ

១១. វិធាន ១០៦ (៤) មិនបានចែងច្បាស់លាស់ ដោយសារតែផ្ដោតតែទៅលើ "សេចក្ដីជូនដំណឹង ឬ បណ្ដឹងសាទុក្ខភ្លាមៗ" តែបញ្ជាក់ថា ការផ្ដល់សិទ្ធិជាលាយលក្ខណ៍អក្សរ "ត្រូវតែភ្ជាប់ជាមួយនឹងបណ្ដឹងសាទុក្ខ"។ វាហាក់ដូចជាថា ការផ្ដល់សិទ្ធិជាលាយលក្ខណ៍អក្សរគឺត្រូវភ្ជាប់ជាមួយនឹងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ឬ បណ្ដឹងសាទុក្ខភ្លាមៗ។ តែវិធានផ្ទៃក្នុងមិនបានហាមឃាត់ នួន ជា មិនឲ្យដាក់ជូនដោយឡែកពីគ្នានូវការផ្ដល់សិទ្ធិជាលាយលក្ខណ៍អក្សរ ដោយបន្ថែមទៅនឹងការភ្ជាប់ជាមួយនឹងសេចក្ដីជូនដំណឹងនេះទេ។

### II. សំណើរបស់ នួន ជា សុំធានាសិទ្ធិរបស់គាត់ ដើម្បីជូនដំណឹងដល់សាធារណជនឲ្យឆាប់ពីការវិវឌ្ឍន៍នៃសំណុំរឿងរបស់គាត់ បើទោះបីដំណើរការនីតិវិធីមានភាពយឺតយ៉ាវ

១២. សាលក្រមត្រូវបានប្រកាសនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ មានរយៈពេលជិតពីរឆ្នាំបន្ទាប់ពីសេចក្ដីសន្និដ្ឋានបិទការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្ដី នៅក្នុងសំណុំ

[10] ការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅក្នុង អនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងធ្វើនយោបាយ ត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងមាត្រា ៣១ នៃ រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា "ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ"។

រឿង ០០២/០២[11]។ នៅភ្លាមៗបន្ទាប់ពីប្រកាសសាលក្រមនេះ លោក នួន ជា បានណែនាំមេធាវីរបស់គាត់ដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ និង បានផ្ដល់សិទ្ធិជាលាយលក្ខណ៍អក្សរដល់មេធាវីរបស់គាត់ក្នុងការធ្វើបណ្ដឹងសាទុក្ខនេះ ។

១៣. ដោយពិចារណាពីទំហំ និង វិសាលភាពរបស់សាលក្រម ភាពស្មុគ្រស្មាញរបស់សំណុំរឿងនេះ និង ធនធានដ៏មានកម្រិតរបស់ក្រុមមេធាវីការពារក្ដី ដើម្បីការពារសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បង្ខំឲ្យមេធាវីការពារក្ដីស្នើសុំបន្ថែមថេរវេលារយៈពេលយ៉ាងតិច ១៥០ ថ្ងៃ (សរុប ១៨០ ថ្ងៃ) ដើម្បីដាក់សេចក្ដីជូនដំណឹងនៃបណ្ដឹងសាទុក្ខរបស់ នួន ជា[12]។

១៤. ដើម្បីការពារសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះ*ជាសាធារណៈ* និង ដោយយុត្តិធម៌ វាក៏តម្រូវឲ្យ នួន ជា ទទួលបានឱកាសជូនដំណឹងដល់សារណៈជនឲ្យបានឆាប់នៃគោលបំណងរបស់គាត់ក្នុងការប្ដឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមនោះ។ ដោយមិនគិតអំពីកាលបរិច្ឆេទដែល នួន ជា ដាក់ជូនសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ដែលកាលបរិច្ឆេទនេះវានឹងកំណត់ដោយលក្ខណៈនៃសាលក្រម។

១៥. អាស្រ័យហេតុនេះ ដោយពិចារណាថាមិនមានបទប្បញ្ញត្តិនៅក្នុងវិធានផ្ទៃក្នុងរារាំងចំនុចនេះ មេធាវីការពារក្ដីស្នើថា ការផ្ដល់សិទ្ធិដែលដាក់ភ្ជាប់ជាមួយនេះ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងជាបន្ទាន់ និង ក្រោយមកត្រូវភ្ជាប់ជាមួយសេចក្ដីជូនដំណឹងនៃបណ្ដឹងសាទុក្ខរបស់គាត់ អនុលោមតាមវិធានផ្ទៃក្នុង វិធាន១០៦(ក)។

## III. សំណើរបស់ នួន ជា គឺជាផលប្រយោជន៍ខាងយុត្តិធម៌

[11] **E1/523.1** ប្រតិចារិកសវនាការ ថ្ងៃទី ១៩ មិថុនា ២០១៧ ទំព័រ ២ បន្ទាត់ ១៨ ដល់ ទំព័រ ១១២ បន្ទាត់ ២០។ **E1/524.1**, ប្រតិចារិកសវនាការ ថ្ងៃទី ២៦ មិថុនា ២០១៧ ទំព័រ ២ បន្ទាត់ ២៣ ដល់ ទំព័រ ១៣០ បន្ទាត់ ១៥។

[12] **F40/1.1** "សំណើលើកទីមួយសុំបន្ថែម" កថាខណ្ឌ ១ (ក) និង ៦១ (ក)។

១៦. នៅទូទាំងក្នុងសំណុំរឿង០០២/០២ ការវាយតំលៃវេជ្ជសាស្ត្រលើ នួន ជា ត្រូវបានធ្វើឡើងជាទៀងទាត់[13]។

១៧. នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៧ ដោយបន្តពីការអនុវត្តជាយូរមកហើយអង្គជំនុំជម្រះសាលាដំបូងបានចាត់តាំងអ្នកជំនាញពីររូបដើម្បីវាយតំលៃសម្បទារបស់ នួន ជា ក្នុងការចូលរួមការជំនុំជម្រះ[14]។ នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៨ អ្នកជំនាញវាយការណ៍ថា "នួន ជា មានអាយុ ៩១ ឆ្នាំ មានសភាពទ្រុឌទ្រោម ហើយប្រឈមនឹង ការចុះខ្សោយខ្លាំងផ្នែកមុខងារផ្សេងៗនៃរាងកាយ"[15]។

១៨. នៅពេលនេះ នួន ជា មានអាយុ ៩៣ ឆ្នាំ។ វាពិតណាស់ថា ការវាយតំលៃខាងលើរបស់អ្នកជំនាញនឹងកាន់តែពាក់ព័ន្ធថែមទៀតនៅពេលនេះ។ [redacted]។

១៩. អនុលោមតាមមាត្រា ៧ (១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មរណភាពនៃជនជាប់ចោទជាមូលហេតុនៃការរំលត់បណ្តឹងអាជ្ញាប្រឆាំងនឹងគាត់នៅ អវតក។ វិធាន ២៣ ស្ទួន (៦) នៃវិធានផ្ទៃក្នុងចែងថា ក្នុងករណីជនជាប់ចោទ ឬ ជនត្រូវចោទទទួលមរណភាព ដំណើរនីតិវិធីបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អវតក ចំពោះជនត្រូវចោទ ឬ ជនជាប់ចោទ

---

[13] **E460/4** "សេចក្តីសម្រេចលើកទីប្រាំមួយ ស្តីពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនការ" ថ្ងៃទី ២៧ កុម្ភៈ ឆ្នាំ ២០១៨ កថាខណ្ឌ ៣ ("សេចក្តីសម្រេចលើកទីប្រាំមួយ")។

[14] **E460** "ដីកាចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងដីកាកំណត់កាលបរិច្ឆេទនៃការវាយតម្លៃ" ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៧។

[15] **E460/4** "សេចក្តីសម្រេចលើកទីប្រាំមួយ" កថាខណ្ឌ ៨។

[16] [redacted]។

នឹងត្រូវបញ្ចប់។ អង្គជំនុំជម្រះសាលាដំបូងប្រឈមនឹងកាលៈទេសៈនេះ។ ឧទាហរណ៍ បន្ទាប់ពីមរណៈភាពរបស់ អៀង សារី នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣[17] និង បាន សម្រេចបញ្ចប់កិច្ចដំណើរនីតិវិធីទាំងអស់ប្រឆាំងនឹងគាត់[18]។

២០. ហេតុដូច្នេះនៅក្នុងករណី នួន ជា ទទួលមរណភាពភ្លាមៗ នោះកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនឹងត្រូវបញ្ចប់ភ្លាមដែរ។ ប្រសិនហេតុការណ៍នេះកើតឡើងនៅមុនការដាក់សេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខរបស់ នួន ជា នោះបំណងរបស់គាត់ក្នុងការធ្វើបណ្តឹងសាទុក្ខនេះនឹងមិនត្រូវបានលាតត្រដាងដល់សាធារណជនជាផ្លូវការនោះទេ បើទោះបីជាត្រូវលើកឡើងនៅក្នុងសំណើលើកទីមួយសុំបន្ថែមថេរវេលាក៏ដោយ។

២១. ដោយពិចារណាលើអាយុ [redacted] និង ពេលវេលាដ៏វែងដែលអាចរំកិលទៅនៅមុខការដាក់សេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខ ក្រុមមេធាវីការពារក្តីយល់ឃើញថា វាមានសារសំខាន់ជាទីបំផុត និង ជាប្រយោជន៍ខាងយុត្តិធម៌ផង ដែលថា លិខិតផ្តល់សិទ្ធិដល់សហមេធាវីរបស់គាត់ដើម្បីដាក់បណ្តឹងសាទុក្ខជំទាស់នឹងសាលក្រម ត្រូវដាក់ចូលក្នុងសំណុំរឿងជាបន្ទាន់ បន្ថែមពីលើការដាក់ភ្ជាប់ជាមួយសេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខ ដោយអនុលោមតាមវិធាន ១០៦ (៤) នៃវិធានផ្ទៃក្នុង។

## ផ្នែកទី ៥. សំណើសុំ

២២. សម្រាប់ហេតុផលដែលបានបញ្ជាក់នៅទីនេះ មេធាវីការពារក្តីស្នើអង្គជំនុំជម្រះសាលាដំបូងដាក់បញ្ចូលលិខិតរបស់ នួន ជា ដែលផ្តល់សិទ្ធិឱ្យសហមេធាវីរបស់គាត់ដើម្បីដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម នៅក្នុងសំណុំរឿង ដោយដាក់ចំណាត់ថ្នាក់ជាឯកសារ

[17] **E270/1** "សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនិងជនជាប់ចោទ អៀង សារី" ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ("ការបញ្ចប់នីតិវិធីប្រឆាំងនឹង អៀង សារី")។

[18] **E270/1** "ការបញ្ចប់នីតិវិធីប្រឆាំងនឹង អៀង សារី") ទំព័រ ៣។

សាធារណៈ និងផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់ អវតក នៅមុនការដាក់សេចក្ដីជូនដំណឹងនៃបណ្ដឹងសាទុក្ខរបស់គាត់។

**សហមេធាវីការពារក្ដីលោក នួន ជា**

**សុន អរុណ** Doreen CHEN